# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## ការិយាល័យអប់រំកុមារមុនថ្នាក់មត្តេយ្យ

### មជ្ឈមណ្ឌលអប់រំ

440 N. BROAD STREET, 2nd FLOOR
PHILADELPHIA, PENNSYLVANIA 19130-1099
ទូរស័ព្ទ៖ ២១៥-៤០០-៤២៧០ ទូរសារ៖ ២១៥-៤០០-៤២៧៥

RENEE QUEEN JACKSON
*នាយិការង*

MICHELLE LINDER-COATES
*នាយិកាប្រតិបត្តិ, Bright Futures/Partners*

JOY DILJOHN
*នាយិកាប្រតិបត្តិ, PreK Head Start*

ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៣

ជូនចំពោះមាតាបិតា និងអាណាព្យាបាល៖

លោកអ្នកទទួលលិខិតនេះ ដោយសារបច្ចុប្បន្ននេះកូនរបស់លោកអ្នករៀនក្នុងកម្មវិធីសម្រាប់កុមារមុនថ្នាក់មត្តេយ្យនៅអាគារដែលគេជួល ហើយមានអាយុដែលអាចរៀនបន្តក្នុងកម្មវិធីសម្រាប់ឆ្នាំសិក្សា២០១៣-២០១៤។

ដូចលោកអ្នកបានជ្រាបមកហើយថា ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា កំពុងបន្តការខិតខំដើម្បីកែលម្អការប្រើធនធាន ដើម្បីរក្សាទុក និងបង្កើនការបម្រើផ្សេងៗដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេ។ ជាផ្នែកមួយនៃការព្យាយាមនេះ ការិយាល័យអប់រំកុមារមុនថ្នាក់មត្តេយ្យ ត្រូវតែផ្លាស់កម្មវិធីរបស់គេទៅកន្លែងផ្សេង ដើម្បីសន្សំធនធាន និងផ្តល់ការបម្រើផ្នែកអប់រំមុនថ្នាក់មត្តេយ្យដល់កុមារ ឲ្យបានច្រើនតាមការដែលអាចធ្វើទៅបាន។ ក្នុងខណៈដែលយើងរៀបចំកម្មវិធីមុនថ្នាក់មត្តេយ្យជាថ្មីឡើងវិញ តាមវិធីសាស្ត្ររបស់យើង យើងខ្ញុំនឹងពឹងផ្អែកទៅលើការគាំទ្រពីកន្លែងមើលថែក្មេង ដែលជាដៃគូនៅក្នុងសហគមន៍របស់យើង ក្នុងការផ្តល់កម្មវិធីមុនថ្នាក់មត្តេយ្យ ដែលមានកន្លែងក្នុងកំឡុងពេលនៃការរៀបចំនេះ។ កូនរបស់លោកអ្នកនឹងនៅកន្លែងបច្ចុប្បន្នជាបន្ត រហូតដល់ចប់ឆ្នាំសិក្សានេះ។

ឲ្យតែកូនរបស់លោកអ្នកនៅតែចុះឈ្មោះរៀនក្នុងកម្មវិធីមុនថ្នាក់មត្តេយ្យរហូតដល់ចប់ឆ្នាំសិក្សានេះ គេនឹងផ្តល់កន្លែងឲ្យពួកគេ នៅក្នុងកម្មវិធីមុនថ្នាក់មត្តេយ្យក្នុងឆ្នាំ២០១៣-២០១៤ នៅកន្លែងផ្សេងទៀតតាមការជ្រើសរើសរបស់លោកអ្នក។

មាតាបិតានឹងទទួលព័ត៌មានតាមសំបុត្រពី ការិយាល័យអប់រំកុមារមុនថ្នាក់មត្តេយ្យ នៅខែមេសា ជាមួយបញ្ជីឈ្មោះនៃទីកន្លែងដែលគេនឹងផ្តល់កម្មវិធីមុនថ្នាក់មត្តេយ្យ។ គេនឹងសុំឲ្យមាតាបិតាជ្រើសរើសទីកន្លែងបី តាមលេខរៀងដែលចង់បាន។ អ្នកធ្វើការខាងកិច្ចការសង្គមកិច្ចក្នុងកម្មវិធីមុនថ្នាក់មត្តេយ្យរបស់យើងខ្ញុំ និងបុគ្គលិកដទៃទៀត នឹងជួយដល់ក្រុមគ្រួសារ ក្នុងកំឡុងពេលនៃការរៀបចំនេះ។

បើមាន សំណួរ ការបារម្ភ ឬមានការផ្លាស់ប្តូរព័ត៌មានរបស់លោកអ្នក សូមទាក់ទងទៅ Myra Frink ឬ Faye Moore។

- ទូរស័ព្ទលេខ ២១៥-៤០០-៤២៧០ prompt #1, option #2
- ទូរសារលេខ ២១៥-៤០០-៤២៧៥ Attention: Family Services
- អ៊ីមែល rloadholt@philasd.org

សូមអរគុណចំពោះការអត់ធ្មត់ និងការយោគយល់របស់លោកអ្នក ក្នុងពេលដែលគ្មានស្ថេរភាពនេះ។

ដោយសេចក្តីស្មោះត្រង់

Joy Diljohn

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer